## ១-ចក្ខុវិស័យ

ធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍបៃតង។

## ២-បេសកកម្ម

ក្រសួងបរិស្ថាន ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនគ្រប់រូបនិងគ្រប់ជំនាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងបរិស្ថានបានដាក់ចេញនូវគោលបំណងគោលនយោបាយចម្បងៗគឺ៖

-លើកកម្ពស់ការវិនិយោគបៃតង តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត ផលិតកម្មវៃឆ្លាត ការដឹកជញ្ជូនបៃតង ការគ្រប់គ្រងសំរាមសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់ ការគ្រប់គ្រងគុណភាពខ្យល់ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការពង្រីកលំហបៃតង និងគាំទ្រសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន។

-ពង្រឹងក្របខណ្ឌគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនឹងបរិស្ថាន ទឹក ដី ខ្យល់ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ និងការទូតបៃតង។

-បន្តអភិវឌ្ឍស្ថាប័ន បង្កើនសមត្ថភាពមន្ត្រីជំនាញ និងចំណេះដឹងបច្ចេកទេស ទាំងការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍លើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតងសន្តិសុខទឹក ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចនូវគោលបំណងគោលនយោបាយខាងលើ ក្រសួងបរិស្ថាន បានដាក់ចេញកម្មវិធីគាំទ្រចំនួន ៤ រួមមាន៖

**កម្មវិធីទី១៖** កិច្ចគាំពារបរិស្ថាន ដោយផ្តោតទៅលើការកាត់បន្ថយ និងទប់ស្កាត់ផលប៉ះពាល់សុខភាពសាធារណៈ ជីវៈចម្រុះ និងគុណភាពបរិស្ថាន ពីគ្រប់សកម្មភាពអភិវឌ្ឍន៍។

**កម្មវិធីទី២៖** ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិនិងការអភិវឌ្ឍសហគមន៍មូលដ្ឋាន ដោយផ្តោតទៅលើការធានានូវការគ្រប់គ្រង ការថែរក្សា ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ក្នុងតំបន់ការពារធម្មជាតិ ដើម្បីជំរុញភាពបៃតង និងធានាបាននូវនិរន្តរភាពធនធានធម្មជាតិ និងការលើកកម្ពស់ជីវភាពប្រជាសហគមន៍មូលដ្ឋានប្រកបដោយនិរន្តរភាព។

**កម្មវិធីទី៣៖** ការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព ដោយផ្តោតសំដៅទៅលើ ការសម្របសម្រួលលើការរៀបចំក្របខណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យបរិស្ថាន ដើម្បីធានាដល់ការលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។

**កម្មវិធីទី៤៖** សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ ដោយផ្តោតទៅលើ ការពង្រឹងការអនុវត្តរដ្ឋបាលទំនើបក្នុងវិស័យបរិស្ថាន និងការលើកកម្ពស់ចំណេះដឹងបរិស្ថានដល់សាធារណៈជន។

## ៣-ថវិកាកម្មវិធីឆ្នាំ ២០២៤

| | |
|---|---|
| សរុបរួម | ៩៦ ៩៤៦,០ លានរៀល |
| -សរុបរដ្ឋបាលកណ្តាល | ៤៨ ៥៥១,០ លានរៀល |
| -សរុបមន្ទីររាជធានី-ខេត្ត | ៤៨ ៣៩៥,០ លានរៀល |
| **កម្មវិធីទី១៖** | ២ ០០១,២ លានរៀល |
| -រដ្ឋបាលកណ្តាល | ១ ៧២៩,០ លានរៀល |
| -មន្ទីរបរិស្ថានរាជធានី-ខេត្ត | ២៧២,២ លានរៀល |
| **កម្មវិធីទី២៖** | ៧ ២៣៦,២ លានរៀល |
| -រដ្ឋបាលកណ្តាល | ៥ ៣៥២,០ លានរៀល |
| -មន្ទីរបរិស្ថានរាជធានី-ខេត្ត | ១ ៨៨៤,២ លានរៀល |
| **កម្មវិធីទី៣៖** | ១ ៦០៦,៧ លានរៀល |
| -រដ្ឋបាលកណ្តាល | ១ ៥៨៦,០ លានរៀល |
| -មន្ទីរបរិស្ថានរាជធានី-ខេត្ត | ២០,៧ លានរៀល |
| **កម្មវិធីទី៤៖** | ៨៦ ១០១,៩ លានរៀល |
| -រដ្ឋបាលកណ្តាល | ៣៩ ៨៨៤,០ លានរៀល |
| -មន្ទីរបរិស្ថានរាជធានី-ខេត្ត | ៤៦ ២១៧,៩ លានរៀល |

# ថវិកាប្រជាពលរដ្ឋ ២០២៤

Citizen Budget

Fiscal Year 2024

# ក្រសួងបរិស្ថាន

Ministry of Environment



អាសយដ្ឋាន៖ អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូ អមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទលេខ៖ ០២៣ ២៣៥ ០០៤/ ០២៣ ២៣៥ ០០៦
គេហទំព័រ ៖ https://www.moe.gov.kh/